| | - **ក្លឹបហ្វ្រេនឡ:** កំពុងផ្តល់សេវាសកម្មភាពផ្នែកវប្បធម៌ផ្សេងៗ ចំនួន ១០០,000 រួមមាន រាំ ល្ខោន បណ្ណាល័យ គំនូរ ដល់កុមារទាំងអស់នៅមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងមួយឆ្នាំ<br>- ក្លឹបហ្វ្រេនឡនឹងបើកសម្រាប់កុមារ/យុវវ័យនៅតាមថ្នល់ចំនួន ២ ដងក្នុងមួយសប្តាហ៍ ដោយផ្តល់សេវានៃសកម្មភាពផ្នែកវប្បធម៌ និងកីឡាចំនួន ៣,៥00ដង ដល់ពួកគេ<br>- ក្លឹបហ្វ្រេនឡកំពុងរៀបចំសកម្មភាពទៅខាងក្រៅសម្រាប់កុមារ និងយុវវ័យនៅក្នុងមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្តល់សេវាកម្មចំនួន ១,២00 ក្នុងមួយឆ្នាំ | **ក្លឹបហ្វ្រេនឡ:** ជាមណ្ឌលអប់រំរបស់អង្គការមិត្តសំឡាញ់ ដែលកុមារ/យុវវ័យអាចអនុវត្តន៍សកម្មភាពកំសាន្តសប្បាយ និងវប្បធម៌ រួមមាន កីឡា គំនូរ ផាត់ពណ៌ បណ្ណាល័យ រាំ និងតន្ត្រី។<br>- ក្លឹបហ្វ្រេនឡ កំពុងផ្តល់សេវាផ្នែកវប្បធម៌ផ្សេងៗចំនួន ២០,0៥៧ (ស្រី១,១00) រួមមានៈ រាំ ល្ខោន បណ្ណាល័យ គំនូរ ដល់កុមារទាំងអស់ នៅមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលណ្តុះបណ្តាលវិជ្ជាជីវៈ)។<br>- ក្លឹបហ្វ្រេនឡ បានបើកសម្រាប់កុមារ/យុវវ័យមកពីក្រៅចំនួន ២ដងក្នុងមួយ សប្តាហ៍ ដោយផ្តល់សេវានៃសកម្មភាពផ្នែកវប្បធម៌ និងកីឡាចំនួន ៤២៨ ដង (ស្រី៨៥ដង) ដល់ពួកគេ។<br>- ក្លឹបហ្វ្រេនឡបានរៀបចំសកម្មភាពទៅខាងក្រៅសម្រាប់កុមារនិងយុវវ័យ នៅក្នុង |

| | | |
|---|---|---|
| | | មជ្ឈមណ្ឌលអប់រំនិងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញជីវិត ដោយផ្តល់សេវាកម្មចំនួន ៩៥ដង (ស្រី៣៥ដង)។<br>**ព្រឹត្តិការណ៍និងរាំណកសម្គាល់ពិសេស**<br>- កុមារ/យុវវ័យចំនួន ៨៦ (ស្រី ១៨នាក់) បានចូលរួមសម្តែង ថ្ងៃបុណ្យទិវាសិទ្ធិកុមារអន្តរជាតិ នៅអង្គការមិត្តសំឡាញ់ដែលមានអ្នកចូលរួមចំនួន ៤៨០ នាក់ នាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១២។<br>- កុមារ/យុវវ័យចំនួន ៣៩ (ស្រី១៥នាក់) បានចូលរួមការប្រកួតកីឡាវាយប៉េងប៉ុង នៅក្លឹបហ្វ្រេនដ្សនៃអង្គការមិត្តសំឡាញ់នាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១២។<br>- កុមារ/យុវវ័យចំនួន ៨៦ នាក់(ស្រី ១៥នាក់) បានចូលរួមប្រកួតកីឡា រួមមានកីឡាវាយប៉េងប៉ុង ប៉ាតាក្រូ និងហែលទឹក នៅឯពហុកីឡាដ្ឋានជាតិជាមួយសិស្សនៃអង្គការភាពញញឹមនៃកុមារ។ ជាលទ្ធផលកុមារមិត្តសំឡាញ់បានទទួលជ័យលាភីលេខ១ និងលេខ២ ។ យុវវ័យ០៨ (ស្រី ០៨នាក់)បានចូលរួមប្រឡងចំរៀងនៅទូរទស្សន៍អាស៊ីអគ្នេយ៍ក្រោមប្រធានបទ "ស្រីស្អាតប្រុសស្អាតរបស់ស្ពាយ" នាថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១២។<br>- កុមារចំនួន២៦នាក់(ស្រី១៣នាក់)បានចូលរួមសម្តែងក្នុងទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀននៅអង្គការមិត្តសំឡាញ់ ដែលមានអ្នកចូលរួមចំនួន ៥៧០នាក់ នាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១២។ |
| ៤.៤<br>**ក្រុមសមាហរណកម្ម**<br>ផ្តល់ការគាំទ្រ ដល់កុមារ | **សមាហរណកម្ម:**<br>- បទដ្ឋាននៃនីតិវិធីពីសមាហរណកម្ម (SoPs)នឹងកែលំអ បកប្រែ និងដំណើរការដោយក្រុមការងារនៅចុងឆ្នាំ ២០១២។ | **សមាហរណកម្ម:**<br>អង្គការមិត្តសំឡាញ់ត្រូវបានអញ្ជើញពីមន្ទីរសង្គមកិច្ចរាជធានី/ខេត្តចំនួន ០៨ រួមមាន រាជធានីភ្នំពេញ កំពង់ស្ពឺ ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រៃវែង និង |

| | | |
|---|---|---|
| ២០០ នាក់ក្នុងមួយឆ្នាំដើម្បីសមាហរណកម្មទៅកាន់ គ្រួសារ (គ្រួសារ បង្កើត គ្រួសារសាច់ញាតិ និងគ្រួសារធម៌) នៅតាមបណ្តាខេត្តនានា។ | - កិច្ចសហការជាមួយរាជរដ្ឋាភិបាល និងអង្គការដៃគូត្រូវបានចាប់ផ្តើមតាមរយៈការប្រជុំនិងការបណ្តុះបណ្តាល<br>- នឹងរៀបចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ ចំនួន៤ដងក្នុង១ ឆ្នាំ<br>- កុមារចំនួន ១០០ នាក់ បានគាំទ្រលើការសមាហរណកម្មគ្រួសាររបស់ពួកគេ (រួមបញ្ចូលគ្រួសារផ្ទាល់ គ្រួសារសាច់ញាតិ )ឬរស់នៅឯករាជ្យ នៅក្នុង ខេត្តរបស់ពួកគេក្នុង១ ឆ្នាំ<br>- កុមារចំនួន១០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅកាន់គ្រួសារធម៌ក្នុង១ ឆ្នាំ<br>- កុមារចំនួន ៥០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅសាលារដ្ឋក្នុងខេត្តរបស់គេក្នុង១ ឆ្នាំ។<br>- កុមារចំនួន ៣០០ នាក់ នៅសាលារដ្ឋ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងខេត្តរបស់ពួកគេ ក្នុង១ ឆ្នាំ<br>- យុវវ័យចំនួន ២០នាក់ នឹងជួយស្វែងរកការងារឱ្យធ្វើ របង្កើតមុខរបរ ដោយខ្លួនឯងនៅខេត្តរបស់ពួកគេ ក្នុង១ ឆ្នាំ<br>- យុវវ័យចំនួន ៧០ នាក់នឹងត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងខេត្តរបស់ពួកគេក្នុង១ ឆ្នាំ<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១៥ គ្រួសារ នឹងទទួលបានគាំទ្រឱ្យត្រឡប់ទៅស្រុកកំណើតវិញក្នុង ១ ឆ្នាំ<br>- គ្រួសារចំនួន១០ នឹងទទួលបានការបណ្តុះបណ្តាល និងគាំទ្រសំរាប់អាជីវកម្មខ្នាតតូចនៅក្នុងខេត្តរបស់ពួកគេក្នុង១ ឆ្នាំ | បន្ទាយមានជ័យ ដើម្បីចូលរួមកិច្ចប្រជុំស្តីពីការសហការលើការងារ សមាហរណកម្ម។<br>- បានសហការជាមួយមន្ត្រីសង្គមកិច្ច និងអង្គការដៃគូលើការងារ សមាហរណកម្ម រួមមានៈ ការស្វែងរក ការវាយតម្លៃ ផែនការគ្រួសារ សមាហរណកម្ម និងការតាមដាន នៅ ២៤ខេត្ត/ ក្រុង។<br>- បានរៀបចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ចំនួន ១ដង ក្នុងត្រីមាសនេះនៅក្រសួងសង្គមកិច្ច រាជធានីភ្នំពេញ។<br>- កុមារចំនួន ២៦នាក់ (ស្រី០៦នាក់)បានគាំទ្រលើការសមាហរណកម្ម គ្រួសាររបស់ពួកគេដែលនៅខេត្ត។<br>- កុមារចំនួន ០១នាក់(ប្រុស) បានគាំទ្រលើការធ្វើសមាហរណកម្មទៅកាន់គ្រួសារនៅខេត្តពោធិ៍សាត់ដើម្បីចិញ្ចឹមរយៈពេលវែង។<br>- កុមារចំនួន ២៤៥នាក់ (ស្រី៩៥នាក់)បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋ ក្នុងខេត្តរបស់ពួកគេ និងទទួលបានសម្ភារៈសិក្សា។<br>- យុវវ័យចំនួន ០៦នាក់(ស្រី ០១នាក់) បានជួយស្វែងរកការងារឱ្យធ្វើ និងបង្កើតមុខរបរដោយខ្លួនឯង នៅខេត្តរបស់ពួកគេ ក្នុងត្រីមាសនេះ។<br>- យុវវ័យចំនួន ១៨នាក់ (ស្រី០២នាក់)ត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងខេត្តរបស់ពួកគេ។<br>- គ្រួសារចំនួន ៣ គ្រួសារ បានទទួលវគ្គបណ្តុះបណ្តាល និងគាំទ្រអាជីវកម្មខ្នាតតូចនៅខេត្តរបស់ពួកគេ ។<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ២គ្រួសារ បានគាំទ្រឱ្យតឡប់ទៅស្រុកកំណើតវិញខេត្តកំពង់ចាម តាមរយៈការគាំទ្រអាជីវកម្មខ្នាតតូច។ |

| | | |
|---|---|---|
| | - កុមារ/យុវវ័យចំនួន ២៥នាក់ នឹងទទួលបានគាំទ្រក្នុងការទទួលអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត នៅខេត្តរបស់ពួកគេក្នុង១ឆ្នាំ | |
| **៤.៥ ដោយមានការគាំទ្រពីសង្គមអាជីវកម្មសង្គមកិច្ច (FSB), មិត្តសំឡាញ់ មានចិរភាព ៥០ %** | ចំណូលរបស់អង្គការមិត្តសំឡាញ់តាមរយៈអាជីវកម្ម:<br>ចំណាយសរុបរបស់អង្គការមិត្តសំឡាញ់:<br>និរន្តភាព: ៥០ %<br>**សិប្បកម្មតាមផ្ទះ**<br>- គ្រួសារចំនួន១២៥ នឹងចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣៧០នាក់ បានទទួលផលពីគម្រោងនេះ ក្នុង១ឆ្នាំ ។<br>- គ្រួសារសិប្បកម្មតាមផ្ទះថ្មីចំនួន ២៥ គ្រួសារ និងអាណាព្យាបាលចំនួន ១២៥នាក់ នឹងទទួលបានការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលផលិតកម្ម (ប្រេន្ទអ៊ិនធើណាសិនណលនិងអណ្តូង)<br>- យុវវ័យចំនួន២០នាក់នឹងទទួលបានគាំទ្រឱ្យមានការងារតាមរយៈអាជីវកម្មសង្គមកិច្ច (មិត្តសំឡាញ់និងប្រេន្ទអ៊ិនធើណាសិនណល)<br>- ការលក់ផលិតផលពីសិប្បកម្មតាមផ្ទះក្នុងហាងលក់ទំនិញប្រេន្ទ អេន ស្តាហ្វ ហាងទូចទូច ការលក់ក្នុងស្រុក និងអន្តរជាតិ នឹងបង្កើនប្រាក់ចំណូលចំនួន ៣០៧,០០០ ដុល្លារ ដែលមាននិរន្តភាពចំនួន៥០ %<br>**មជ្ឈមណ្ឌលផលិតកម្ម**<br>- អាណាព្យាបាលចំនួន ៧០នាក់ កំពុងទទួលបានការបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះ និងអាជីវកម្មខ្នាតតូច<br>- អាណាព្យាបាលចំនួន ១៥ នាក់ កំពុងធ្វើការបោះពុម្ព | ចំណូលរបស់អង្គការមិត្តសំឡាញ់តាមរយៈអាជីវកម្ម: ២៣២,៦៦០.៦៦ ដុល្លារ<br>ចំណាយសរុបរបស់អង្គការមិត្តសំឡាញ់: ១២៩,៥៣២.៤៩ ដុល្លារ<br>និរន្តភាព: ៤៤.៩៩ %<br>**សិប្បកម្មតាមផ្ទះ**<br>- មាតាបិតាសិស្សចំនួន ៩០ (រួមបញ្ចូលថ្មី ០២) បានចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារ ចំនួន ៣០៧នាក់ (ស្រី១០៦នាក់) បានទទួលផលពីគម្រោងនេះ។<br>- មានគ្រួសារសិប្បកម្មតាមផ្ទះថ្មីចំនួន ០២ គ្រួសារ និងអាណាព្យាបាល ៩០នាក់ បានចូលរួមការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលផលិតកម្ម (ប្រេន្ទអ៊ិនធើណា សិនណល និងអណ្តូង)<br>- យុវវ័យចំនួន ០៤នាក់ បានទទួលការគាំទ្រឱ្យមានការងារតាមរយៈគម្រោងធុរកិច្ចសង្គម (មិត្តសំឡាញ់និងប្រេន្ទអ៊ិនធើណាសិនណល) ចាប់ពី១មករា២០១២។<br>- ការលក់ផលិតផលសិប្បកម្មតាមផ្ទះក្នុង ហាងលក់ទំនិញប្រេន្ទអេនស្តាហ្វ ហាងទូចទូច ការលក់ក្នុងស្រុក និងអន្តរជាតិ កំពុងបង្កើនប្រាក់ចំណូល បានចំនួន ៤៣,២១១.៩៣ ដុល្លារនិងប្រាក់ចំណេញ១៣,០៤៦.១៤ដុល្លារ។<br>**មជ្ឈមណ្ឌលផលិតកម្ម**<br>- អាណាព្យាបាលចំនួន ២៣នាក់ បានទទួលការបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះ និងអាជីវកម្មខ្នាតតូច។<br>- អាណាព្យាបាលចំនួន០៣នាក់ បំពេញការងារលើការបោះពុម្ព |

| | | |
|---|---|---|
| | - **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រួសារចំនួន ១៥០ (រួមបញ្ចូល៤០ គ្រួសារថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារចំនួន ៥៨០នាក់ដែលនឹងទទួលបានផលពីអាជីវកម្មនេះ | - **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល ០៧ គ្រួសារ និងគាំទ្រគ្រួសារចំនួន ១២០ (រួមបញ្ចូល០៧គ្រួសារថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូល របស់ពួកគេ ដោយមានកុមារ ៤៨៥នាក់ (ស្រី២១០ នាក់) បានទទួលផលពីអាជីវកម្មនេះ។ |
| | - **កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ៣០,០០០ដុល្លារ ក្នុង១ ឆ្នាំ | - **កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ១០,២៦៩.៩៣ ដុល្លារ និងប្រាក់ចំណេញ១៥៨.៣៥ ដុល្លារ ។ |
| | - **ផលិតផលមិត្តសំឡាញ់** (សៀវភៅរៀនធ្វើម្ហូបហ្វ្រេនឌ្ស)នឹងអាចរកចំណូលបានចំនួន ៤៥,០០០ដុល្លារ ក្នុងមួយឆ្នាំ (កើនឡើង៤% )និងប្រាក់ចំណេញចំនួន ២៥, ០០០ ក្នុងមួយឆ្នាំ | - **ផលិតផលមិត្តសំឡាញ់** (សៀវភៅរៀនធ្វើម្ហូបហ្វ្រេនឌ្ស)អាចរកចំណូលបានចំនួន ៣,៤២៩.៦៥ ដុល្លារ និងប្រាក់ចំណេញចំនួន ៣,២៥៤.៣៨ ដុល្លារ។ |
| | - **ជំនាញវិជ្ជាជីវៈទាំងអស់** ដើរតួនាទីជាអាជីវកម្មសង្គមកិច្ច | - **ជំនាញវិជ្ជាជីវៈ** បានក្លាយជាធុរកិច្ចរួមមានៈ ថ្នាក់កាត់ដេរ ថ្នាក់ជួសជុលម៉ូតូ/ឡាន ថ្នាក់អគ្គិសនី ថ្នាក់អេឡិចត្រូនិច ថ្នាក់ផ្សារដែក ថ្នាក់ចុងភៅ ថ្នាក់កាត់សក់ និងថ្នាក់កែសម្ផស្ស បង្កើតបានប្រាក់ចំណូល ៩,៥៦៩.៣៣ ដុល្លារ ជាមួយប្រាក់ចំណេញ១,៦៣២.០៣ ដុល្លារ។ |
| | - **កន្លែងធ្វើក្រចក** ស្ថិតនៅខាងក្នុង ហាងហ្វ្រេនឌ្សអនស្តាស់ នៅលើផ្លូវ ១៣ ជិតភោជនីដ្ឋានហ្វ្រេនឌ្ស | - **កន្លែងធ្វើក្រចក** បង្កើតបានប្រាក់ចំណូលចំនួន ១,៨១៦ដុល្លារ និងខាតចំនួន – ១.១១១.៤៣ ដុល្លារ។ |
| | - **វិជ្ជាជីវៈភោជនីយដ្ឋាន** ចំនួន២ (សូមមើលៈ សកម្មភាព ៤.៣) )បានចូលរួមទៅក្នុងអាជីវកម្មសង្គមកិច្ច នឹងទទួលបានប្រាក់ចំណូល ១,១៥៤,០០០ ដុល្លារក្នុង ១ឆ្នាំ ដោយមានប្រាក់ចំណេញ ៣៣៨,០០០ដុល្លារ ក្នុង១ឆ្នាំ។ ភោជនីយដ្ឋានចំនួន ២ នឹងមាននិរន្តភាពរហូតដល់១០០% | - **វិជ្ជាជីវៈភោជនីយដ្ឋាន** ចំនួន២ (សូមមើលៈ សកម្មភាព៤.៣ )បានចូលរួមក្នុងអាជីវកម្មសង្គមកិច្ច ទទួលបានប្រាក់ចំណូល ១៦៤,៣៦៣.៨២ ដុល្លារ និងខាត ១០,៩៩៣.៣៧ ដុល្លារ។<br>**ភោជនីដ្ឋានហ្វ្រេនឌ្ស:** ៨៨,៦១១.៤៨ដុល្លារ ប្រាក់ចំណូល និងខាតៈ ១,២៣០.២៨ ដុល្លារ<br>**ភោជនីដ្ឋានរំដេង:** ៧៥,៧៥២.៣៤ដុល្លារ ប្រាក់ចំណូល និងខាត ៩,៧៦៣.០៩ |

| | | |
|---|---|---|
| | | ដុល្លារ។<br>**ព្រឹត្តិការណ៍និងសំណត់សម្គាល់ពិសេស**<br>- អ្នកគ្រប់គ្រងករណីចំនួន ១១នាក់ (ស្រី៦នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលអាជីវកម្មខ្នាតតូច នៅអង្គការប្រេនឡអ៊ិនធើណាសិនណល នាថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១២ ។<br>- ក្រុមសិប្បកម្មតាមផ្ទះបានបង្កើតផលិតផលថ្មីចំនួន ៥មុខ បន្ថែមទៀតនៅក្នុងត្រីមាសនេះ។<br>- បានផ្គត់ផ្គង់ផលិតផលសិប្បកម្មតាមផ្ទះទាន់ពេលដល់ហាងថ្មីនៃអង្គការប្រេនឡអ៊ិនធើណាសិនណាល នៅសណ្ឋាគារអ៊ិនធើខន។<br>- ក្រុមអាជីវកម្មសង្គម បានចូលរួមតាំងពិព័រណ៍នៅកាហ្វេមិត្តសំឡាញ់ និងភោជនីយដ្ឋាន កាសូលីនា។ |
| **៥.ក្រុមឯកទេសចំនួន ៨ ក្រុមកំពុងផ្តល់ការជួយគាំទ្រកម្មវិធីនៅត្រឹមឆ្នាំ២០១២** | | |
| **៥.១**<br>**ក្រុមឯកទេសលើការការពារកុមារ** | **លទ្ធផលរំពឹងទុក:**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ១០០ករណីនឹងត្រូវបានបំពេញ<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ការវាយតម្លៃគោលការណ៍ការពារកុមារនៅក្នុងមណ្ឌលសំចត មជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់មណ្ឌលស្នាក់នៅបណ្តោះអាសន្ន ទាំងអស់<br>- ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល | **លទ្ធផលសំរេចបាន:**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ២១ករណី បានបំពេញ និងបញ្ជូនទៅអង្គការពាក់ព័ន្ធ អាជ្ញាធរ ដើម្បីអន្តរាគមន៍។<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- អ្នកឯកទេសសុវត្ថិភាពកុមារ បានចូលរួមការប្រជុំក្រុមចំនួន ១២ដង ជាមួយកុមារ/យុវវ័យនៅមណ្ឌលស្នាក់នៅទាំងអស់ ស្តីពីបទបញ្ជាផ្ទៃក្នុង សិទ្ធិកុមារ លើកករណី |

| | | |
|---|---|---|
| | - រៀបចំការស្ទង់មតិលើការស្នាក់នៅរបស់កុមារដែលស្នាក់នៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្នរបស់អង្គការមិត្តសំឡាញ់ រៀងរាល់៣ខែម្ដង<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិក១០០% នឹងទទួលការបណ្ដុះបណ្ដាល និងរំលឹកឡើងវិញលើគោលការណ៍ការពារសិទ្ធិកុមារ<br>- ការបោះឆ្នោតជ្រើសរើសតំណាងកុមារនឹងរៀបចំជារៀងរាល់៦ខែ ក្នុងឆ្នាំ<br>**ឧបករណ៍**<br>- នឹងធ្វើបច្ចុប្បន្នភាពនិងអនុវត្តគោលការណ៍ការពារសិទ្ធិកុមារ<br>- គោលការណ៍ការពារសិទ្ធិកុមារនឹងដាក់បង្ហាញនៅគ្រប់មណ្ឌលទាំងអស់<br>- ធានាថាឧបករណ៍ទាំងអស់មាននៅក្នុងមណ្ឌលនីមួយៗ | សិក្សាមួយចំនួន និងការចែករំលែកព័ត៌មាន។<br>- បានផលិតក្រងរបាយការណ៍ប្រចាំខែ និង ត្រីមាសជូនមិត្តសំឡាញ់ ។<br>- បានរៀបចំការសម្ភាសន៍ប្រចាំត្រីមាស ស្ដីពីសេវាកម្មរបស់អង្គការមិត្តសំឡាញ់ ជាមួយកុមារ/យុវវ័យចំនួន ២៩ (ស្រី០៩នាក់) កំពុងស្នាក់នៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្នទាំង៣ និងមណ្ឌលបន្សាបគ្រឿងញៀន។<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិកតាមថ្នល់ចំនួន ៣៣នាក់ បានទទួលវគ្គរំលឹកឡើងវិញ ស្ដីពីគោលការណ៍ការពារសិទ្ធិកុមារ។<br>- បានចុះមូលដ្ឋានចំនួន ៧៥ ដង នៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្ន មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ មជ្ឈមណ្ឌលអប់រំ និងមណ្ឌលសំចតទាំងអស់ ដើម្បីពង្រឹងដំណើរការនៃការអនុវត្តន៍គោលការណ៍ការពារសិទ្ធិកុមារ និងធានាសុវត្ថិភាពដល់កុមារ ។<br>- ការបោះឆ្នោតជ្រើសរើសតំណាកុមារត្រូវបានឡើងនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១២ ដោយមានកុមារចូលរួមចំនួន ៣២២ នាក់ (ស្រី១២៥នាក់) និងតំណាងកុមារចំនួន ០៧នាក់ ត្រូវបានជាប់ឆ្នោតជាតំណាងមកពីមណ្ឌលស្នាក់នៅបណ្ដោះអាសន្ន ។<br>**ឧបករណ៍**<br>- បានធ្វើបច្ចុប្បន្នភាពលើបទបញ្ជាផ្ទៃក្នុង នៃមជ្ឈមណ្ឌលអប់រំ ដោយមានការចូលរួមពីកុមារ និងបានដាក់ឱ្យអនុវត្តន៍។<br>- សម្ភារៈគោលនយោបាយសម្រាប់ការពារកុមារ បទបញ្ជាផ្ទៃក្នុង និងប្រព័ន្ធរបាយការណ៍បានដាក់បិតនៅលើជញ្ជាំងនៃមណ្ឌលទាំងអស់។ |

| | | |
|---|---|---|
| | | **ព្រឹត្តិការណ៍និងសំណល់សម្គាល់ពិសេស:**<br>- បានចូលរួមសិក្ខាសាលា ស្តីពីបទដ្ឋានអប្បបរមាសម្រាប់កុមារដែល អនាថា ងាយរង គ្រោះ នៅក្រសួងសង្គមកិច្ចនាថ្ងៃទី ២៥ ខែមេនា ឆ្នាំ២០១២។ |
| ៥. ២ ក្រុមឯកទេសវេជ្ជសាស្ត្រ | **លទ្ធផលរំពឹងទុក:**<br>- សេវាព្យាបាលនិងសង្គ្រោះបឋមចំនួន ៨៥,000 នឹងផ្តល់ជូនកុមារ/យុវវ័យ ក្នុងនោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ២៣,000 សេវា<br>- កុមារ/យុវវ័យចំនួន ៨៥0នាក់ នឹងបញ្ជូនទៅនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ១0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យ<br>- អាណាព្យាបាលដែលផ្ទុក មេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ៣0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យចំនួន ៣00នាក់ នឹងទទួលការព្យាបាលជម្ងឺកាមរោគ<br>- អាណាព្យាបាលចំនួន ៩0នាក់ នឹងទទួលការព្យាបាលជម្ងឺកាមរោគ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធត្រួតពិនិត្យនិងប្រមូលទិន្នន័យគឺជាសូចនាករគុណភាពស្តង់ដា នៃកម្មវិធីប្រឡូអ៊ិនធើណាស៊ិនណាលសម្រាប់សកម្មភាពសុខាភិបាល<br>- ការវាយតម្លៃលើការថែរក្សាផ្នែកសុខភាពនៅក្នុងគម្រោងទាំងអស់មានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអ្នកឯកទេសហ៊ីវ/អេដស៍ក្នុងរយៈពេល១ឆ្នាំ | **លទ្ធផលសំរេចបាន:**<br>- សេវាព្យាបាល និងសង្គ្រោះបឋមចំនួន ១៩,០៩២ បានផ្តល់ជូនកុមារ/យុវវ័យក្នុងនោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ៥,១៦១ សេវា ។<br>- កុមារ/យុវវ័យចំនួន ១៨៤នាក់ បានបញ្ជូនទៅនៅមន្ទីរពេទ្យ<br>- កុមារផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន 0៣នាក់ បានទទួលការព្យាបាលនៅមន្ទីរពេទ្យ ។<br>- អាណាព្យាបាលដែលផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន 0៨នាក់ បានទទួលការព្យាបាលនៅមន្ទីរពេទ្យ ។<br>- កុមារ/យុវវ័យចំនួន ៣៧នាក់ បានទទួលការព្យាបាលជម្ងឺកាមរោគ<br>- អាណាព្យាបាលចំនួន ៥២នាក់ បានទទួលការព្យាបាលជម្ងឺកាមរោគ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- តាមរយៈការចុះមូលដ្ឋាន និងតាមដានពីអ្នកឯកទេសគ្លីនិកទាំងអស់មាន អនាម័យល្អបន្ទប់ស្អាត ទម្រង់អង្គភាពរបស់កុមារត្រូវបានបំពេញ និងកន្លែងទុកថ្នាំត្រូវបានរៀបចំយ៉ាងរៀបរាយ។<br>- ការត្រួតពិនិត្យសុខភាពកុមារ/យុវវ័យចំនួន ៦0ដង បានធ្វើជាទៀងទាត់នៅពេល |

| | | |
|---|---|---|
| | - ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិកវេជ្ជសាស្ត្រទាំងអស់នឹងទទួលបានការបណ្តុះបណ្តាលយ៉ាងទៀងទាត់<br>- ជំនួយបច្ចេកទេស នឹងផ្តល់ជារៀងរាល់សប្តាហ៍តាមរយៈការងារនៅតាមមូលដ្ឋានជាមួយក្រុមទាំងអស់<br>- ពង្រឹងកិច្ចសហការរវាងបុគ្គលិកសុខាភិបាលនិងអ្នកគ្រប់គ្រងករណី<br>- ពិនិត្យ ឡើងវិញនិងបញ្ជាទិញសម្ភារៈ វេជ្ជសាស្ត្រតាមតម្រូវការរបស់ក្រុមការងារ<br>**ឧបករណ៍**<br>- សៀវភៅណែនាំនឹងរៀបចំអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៣៥នាក់នឹងត្រូវបានស្វែងរក និងបណ្តុះណ្តាលក្នុងមួយឆ្នាំ<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | កុមារ/យុវវ័យចាប់ផ្តើមចូលរៀននៅអង្គការមិត្តសំឡាញ់ និងមុនពេលបញ្ជូនទៅគ្រួសារ ឬប្រកបមុខរបរ។<br>- បានចងក្រងរបាយការណ៍ប្រចាំខែ និងត្រីមាសដើម្បីផ្ញើរជូនមិត្តសំឡាញ់ មន្ទីរសុខាភិបាលរាជធានីភ្នំពេញនិង ក្រសួងសុខាភិបាល។<br>- បានដឹកនាំធ្វើការវាយតម្លៃលើសេវាសុខភាពនៃអង្គការមិត្តសំឡាញ់ជាមួយបុគ្គលិកពេទ្យចំនួន ១៤(ស្រី០៤នាក់) ដោយមានកិច្ចសហការជាមួយអ្នកស្ម័គ្រចិត្ត នៃអង្គការប្រេន្ទអ៊ិនធើណាសិនណល។<br>**គាំទ្របច្ចេកទេស**<br>- ករណីមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន ៦ករណី រួមមាន បញ្ហាខួរក្បាល បញ្ហាភ្នែក បញ្ហាស្បែកប្រតិកម្ម បានគាំទ្រ និងបញ្ជូនទៅមន្ទីរ ពេទ្យកាល់ម៉ែត មជ្ឈមណ្ឌលស្ថានីតិសម្បទាគៀនឃ្លាំង មិត្តភាពខ្មែរ-សូវៀត មជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងនិងជំងឺអេដស៍សើស្បែក ។<br>- បានចុះមូលដ្ឋានចំនួន ៣៨ដង ក្នុង៥តំបន់ រួមបញ្ចូលទាំងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ផ្ទះបៃតង និងមណ្ឌលសំចតចល័តទាំង ២ផង ដើម្បីជួយអ្នកគ្រប់គ្រង់ករណីនិងប្រធានតំបន់ ក្នុងការគាំទ្រផ្នែកសុខ ភាពដល់កុមារ/យុវវ័យ និងគ្រួសារតាមតំបន់គោលដៅ ។<br>- បុគ្គលិកសង្គម ៤៧នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសុខភាពមាត់ធ្មេញនិងជម្ងឺគ្រុនចាញ់ ។<br>- បុគ្គលិកពេទ្យចំនួន ១៤នាក់(ស្រី ០៤នាក់) បានរួមវគ្គបណ្តុះបណ្តាលស្តីពីសង្គ្រោះបឋម គុណភាពល្អនៃការបង្រៀន ប្រតិកម្មស្បែក ចិត្តសាស្ត្រសង្គម មូលដ្ឋាន |

| | | |
|---|---|---|
| | | គ្រឹះនៃគ្រឿងញៀន សុខភាពបន្តពូជ កាមរោគ និង មេរោគអេដស៍/ជំងឺអេដស៍ ។<br>**ឧបករណ៍**<br>- គោលការណ៍ណែនាំលើសេវាការព្យាបាលបឋម ត្រូវបានបណ្តុះបណ្តាលដល់បុគ្គលិកពេទ្យ ចំនួន ១៣ នាក់ (ស្រី០៣នាក់) ក្នុងត្រីមាសនេះ។<br>**ដៃគូ**<br>- បានទស្សនកិច្ចនៅមន្ទីរពេទ្យកែវសន្ត ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្ម ដោយមានកិច្ចសហការពីអង្គការប្រេទ្យអ៊ិនធើណាសិនណល។<br>**ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ**<br>- បានសហការជាមួយវេជ្ជបណ្ឌិត នៅមជ្ឈមណ្ឌលស្ថានីតិសម្បទាគៀនឃ្លាំង មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យគុន្ធាបុប្ផា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីគាំទ្រ និងព្យាបាលដល់កុមារនិងយុវវ័យដែលឥតបង់ថ្លៃ។<br>- បានចូលរួមការប្រជុំប្រចាំខែជាមួយអង្គការម៉េឌីខាំ និងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ពាក់ព័ន្ធទៅនឹងបញ្ហាផ្នែកសុខភាព ជាមួយអង្គការដៃគូផ្សេងទៀត ។<br>- កុមារនៅមជ្ឈមណ្ឌលអប់រំចំនួន ៥០ (ស្រី ២៣នាក់) បានគាំទ្រលើការព្យាបាលនិងថែទាំសុខភាពមាត់ធ្មេញពីអង្គការOne 2 One នៅមន្ទីរពេទ្យព្រះកិតុមាលា។<br>**ព្រឹត្តិការណ៍និងកំណត់សម្គាល់ពិសេស**<br>- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅបន្តការចុះតម្លៃ ២០ % និងពេទ្យក្រុង ១០ % ចំពោះការព្យាបាលអតិថិជនរបស់អង្គការមិត្តសំឡាញ់។<br>- គ្រួសារដែលរស់នៅសហគមន៍អណ្តូងចំនួន ៦០ គ្រួសារ បានទទួលព័ត៌មានពីការការពារដើម្បីគ្រុនឈាមពីបុគ្គលិកអណ្តូង ។ |

| | | |
|---|---|---|
| **៥.៣ ក្រុមឯកទេសមេរោគអេដស៍/ជម្ងឺអេដស៍** | **លទ្ធផលរំពឹងទុក:**<br>- កុមារចំនួន ២៥០នាក់ នឹងបញ្ជូនទៅធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់<br>- អាណាព្យាបាលចំនួន ៣៥០នាក់ នឹងបានចូលរួមក្រុមគាំទ្រផ្លូវចិត្ត(EGS ) គិតជាចំនួនសេវាស្មើ៤,៥០០<br>- កុមារ/យុវវ័យចំនួន ៥០នាក់ នឹងទទួលថ្នាំពន្យាជីវិត(ARV) និងការព្យាបាលជម្ងឺឱកាសនិយម(OI)<br>- កុមារ/យុវវ័យចំនួន ៥០០នាក់ ដែលឆ្លងនិងរងផលប៉ះពាល់មេរោគអេដស៍/ជម្ងឺអេដស៍នឹងទទួលបានសេវានៅមិត្តសំឡាញ់ឬតាមរយៈមិត្តសំឡាញ់<br>- អាណាព្យាបាលចំនួន ៣០០នាក់ ដែលទទួលរងផលប៉ះពាល់ នឹងទទួលបានសេវាសង្គមនៅមិត្តសំឡាញ់ឬតាមរយៈមិត្តសំឡាញ់<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធីប្លេនអ៊ិនធើណាសិនណលសម្រាប់សកម្មភាព ដែលពាក់ព័ន្ធមេរោគអេដស៍/ជម្ងឺអេដស៍ (បំណិនជីវិត សមាហរណកម្ម ការគាំទ្រគ្រួសារ និងទទួលបាន ការព្យាបាល)<br>- ការវាយតម្លៃលើសកម្មភាព ដែលពាក់ព័ន្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍ (បំណិនជីវិត សមាហរណកម្មការគាំទ្រគ្រួសារ និងការទទួលបានការព្យាបាល)<br>- ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និង រដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយលើគម្រោងមេរោគអេដស៍និងជម្ងឺអេដស៍នៅចុងឆ្នាំ ២០១២ | **លទ្ធផលសំរេចបាន:**<br>- កុមារចំនួន ៤២នាក់ បានបញ្ជូនទៅធ្វើតេស្តឈាមរកមេរោគ អេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។<br>- អាណាព្យាបាលចំនួន ៣៤៩នាក់ បានចូលរួមក្រុមគាំទ្រផ្លូវចិត្ត(EGS ) ប្រចាំសប្តាហ៍ ស្មើនឹងសេវាចំនួន ១,៤០៧ ។<br>- កុមារ/យុវវ័យចំនួន ៥៣នាក់ បានទទួលថ្នាំពន្យាជីវិត(ARV) និងការព្យាបាលជម្ងឺឱកាសនិយម(OI) ជារៀងរាល់សប្តាហ៍។<br>- កុមារ/យុវវ័យចំនួន ៥៤៣នាក់ ដែលឆ្លងនិងរងផលប៉ះពាល់មេរោគអេដស៍/ជម្ងឺអេដស៍ បានទទួលសេវានៅមិត្តសំឡាញ់ឬតាមរយៈមិត្តសំឡាញ់ ។<br>- អាណាព្យាបាលចំនួន ២៥៣នាក់ ដែលទទួលរងផលប៉ះពាល់មេរោគអេដស៍/ជម្ងឺ បានទទួលសេវាសង្គម រួមមាន អាហារ ការជួលផ្ទះ និងការគាំទ្រអាជីវកម្មខ្នាតតូច នៅអង្គការមិត្តសំឡាញ់ ។<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានចុះមូលដ្ឋានចំនួន ២៣ដង ក្នុង៥តំបន់ នៃក្រុមតាមថ្នល់ ផ្ទះបៃតង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំមណ្ឌលសំចតយ័ត ដើម្បីគាំទ្រអ្នកគ្រប់គ្រងករណីនិងអ្នកសម្របសម្រួលក្រុមគាំទ្រ ផ្លូវចិត្តនៅក្នុងតំបន់នីមួយៗរៀង រាល់សប្តាហ៍។<br>- បានចងក្រងរបាយការណ៍ប្រចាំខែ និងត្រីមាសជូនមិត្តសំឡាញ់ ។<br>- បានចុះធ្វើការសង្កេត ២ដង នៅសហគមន៍ទួលសំបូរ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីស្ថានភាពទូទៅ បញ្ហាប្រឈម និងតម្រូវការក្រុមគោលដៅដើម្បីឆ្លើយតបទៅ |

| | | |
|---|---|---|
| | **ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក១០០ % នឹងទទួលបានការបណ្តុះបណ្តាលស្តីពីការយល់ដឹងច្បាស់លាស់ពីមេរោគអេដស៍/ជម្ងឺអេដស៍ ថ្នាំព្យាបាលជីវិត ការបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់។ ល។<br>- នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍ តាមរយៈការងារនៅមូលដ្ឋាន ជាមួយក្រុមតាមថ្នល់និងសមាហរណកម្ម<br><br>**ឧបករណ៍**<br>- សម្ភារៈអប់រំលើមេរោគអេដស៍/ជម្ងឺអេដស៍នឹងត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នភាព ជាប្រចាំ<br>- សៀវភៅជីវប្រវត្តិនឹងត្រូវធ្វើបច្ចុប្បន្នភាពនិងអនុវត្ត<br>- ទម្រង់បន្ថែមនៃការគ្រប់គ្រងករណីនឹងត្រូវបានបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>- សៀវភៅណែនាំស្តីពីការគាំទ្រផ្លូវចិត្ត និងការធ្វើការជាមួយគ្រួសារ ដែលរស់នៅជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍នឹងរៀបចំអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាថ្មីទៀងទាត់<br><br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកដល់ក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៣០នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | នឹងគម្រោងយុទ្ធសាស្ត្រឆ្នាំ២០១២ របស់អង្គការមិត្តសំឡាញ់ ។<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិកតាមចំនួន ១៧នាក់ បានទទួលការបណ្តុះបណ្តាលស្តីពីទម្រង់បន្ថែមធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ និងអាហារបំប៉នសម្រាប់អ្នករស់នៅជាមួយជំងឺអេដស៍ ដោយមានកិច្ចសហការជាមួយបុគ្គលិកស្ម័គ្រចិត្តប្រេនឡអ៊ិនធើណាសិនណល។<br>- បានសហការជាមួយអ្នកជំនាញទេសស្តុរក្ខិភាពកុមារ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការការពារកុមារ និងសិទ្ធិកុមារដល់ក្រុមគាំទ្រផ្លូវចិត្ត (EGS ) ស្ម័គ្រចិត្តមកពីតំបន់នីមួយៗ ។<br>- បានចូលរួមប្រជុំប្រចាំខែជាមួយអ្នកសម្របសម្រួលក្រុមគាំទ្រផ្លូវចិត្តដើម្បីស្វែងរកប្រធានបទ បញ្ហាប្រឈម និងដំណោះស្រាយ ដើម្បីឆ្លើយតបដល់ពួកគេ។<br>- បានជួយគាំទ្រប្រធានក្រុមមាត់ទន្លេ ដើម្បីស្វែងរកទីកន្លែងថ្មី សម្រាប់ប្រជុំក្រុមគាំទ្រផ្លូវចិត្ត(EGS ) បន្ទាប់ពីមណ្ឌលផ្ទះសំណាក់ពេលថ្ងៃបានបិទ ហើយជាលទ្ធផល ក្រុមការងារបានរកឃើញកន្លែងថ្មីនៅវត្តចិនដំដែកក្នុងសង្កាត់ស្រះចកខណ្ឌដូនពេញ ។<br><br>**ឧបករណ៍**<br>- សម្ភារៈអប់រំ ស្តីពីការកាត់បន្ថយការឆ្លងពីម្តាយទៅកូន បានបោះពុម្ពក្នុងត្រីមាសនេះ ហើយនឹងផ្តល់វគ្គបណ្តុះបណ្តាលនៅត្រីមាសបន្ទាប់ ហើយកម្មវិធីសិក្សាក៏បានបញ្ចប់ និងឯកភាពដោយសម្របសម្រួលកម្មវិធីក្នុងកំឡុងពេលនោះផងដែរ។<br><br>**ដៃគូ** |

| | | |
|---|---|---|
| | | - បានទស្សនកិច្ចនៅអង្គការវ៉ាប់ប៊ីតស្កូល ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវា កម្មដោយមានកិច្ចសហការពីអង្គការប្រេទ្យអ៊ិនធើណាសិនណល។<br><u>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:</u><br>- បានចូលរួមប្រជុំជាមួយក្រុមបច្ចេកទេសនៃការថែរក្សានិងព្យាបាល រៀបចំដោយគណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍និងជម្ងឺអេដ៍(HACC) នៅភោជនីយដ្ឋាន ផាកអ៊ុំដែន នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១២ ។<br>- បានចូលរួមកិច្ចប្រជុំវេទិកាអង្គការដៃគូ ស្តីពីការវាយតម្លៃបញ្ចប់ គម្រោងរបស់អង្គការជំនួយរបស់រ៉ិហារដាណីមាក នៅមណ្ឌលដៃគូគ្នា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១២ ។<br>- បានចូលរួមប្រជុំសមាជិកប្រចាំត្រីមាសលើទី៦១ នៃគណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍និងជម្ងឺអេដស៍ (HACC) ដើម្បីចែករំលែកព័ត៌មាននិងលើកឡើងនូវបញ្ហាជួបប្រទះ នៅសណ្ឋាគារសាន់វេ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១២។<br>- បានចូលរួមប្រជុំពេញអង្គលើកទី១៨ ជាមួយក្រុមការងារថ្នាក់ជាតិពហុវិស័យនៃកុមារកំព្រា និងកុមារងាយរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីត យុទ្ធជន យុវនីតិសម្បទា ស្តីពីលទ្ធផលប្រចាំត្រីមាសទី២ និងផែនការប្រចាំត្រីមាសទី៣ ២០១២ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២។<br>- ចូលរួមសិក្ខាសិលាស្តីពី មាត្រដ្ឋាន និងគោលការណ៍ណែនាំលើការថែរក្សា គាំទ្រ និងការពារកុមារកំព្រា និងងាយរងគ្រោះ នៅក្រសួងសង្គមកិច្ច អតីត យុទ្ធជន យុវនីតិសម្បទា នាថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១២ ។ |

| | | |
|---|---|---|
| **៥.៤ ក្រុមឯកទេសលើ ការគ្រប់គ្រងករណី** | **លទ្ធផលរំពឹងទុក:**<br>**ករណីសកម្ម :**<br>- ៥,000 ករណីបុគ្គល<br>- ៥៥0 ករណីគ្រួសារ<br>- ២០ ករណីសហគមន៍<br>**ករណីថ្មីៗ:**<br>- ៧00 ករណីបុគ្គល<br>- ១២០ ករណីគ្រួសារ<br>- ៤ករណីសហគមន៍<br>**ករណីដែលបានបិទ:**<br>- ៣00 ករណីបុគ្គល<br>- ៥0 ករណីគ្រួសារ<br>- ២ករណីសហគមន៍<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណស្តង់ដា នៃកម្មវិធី ប្រូក្រាមអ៊ិនធើណែតសិនណាលសម្រាប់ការគ្រប់គ្រងករណី<br>- ការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងករណី១ដង/ឆ្នាំ<br>- ផងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយដង<br>**ការគាំទ្របច្ចេកទេស** | **លទ្ធផលសំរេចបាន:**<br>**ករណីសកម្មនាត្រីមាសនេះ:**<br>- ២,៥៥៣ (ស្រី៩៣៤) ករណីបុគ្គល<br>- ៤0៧ករណីគ្រួសារ<br>- ១៦ ករណីសហគមន៍<br>**ករណីថ្មីៗ នាត្រីមាសនេះ:**<br>- ១៤៩ (ស្រី៤៩)ករណីបុគ្គល<br>- ១៦ករណីគ្រួសារ<br>**ករណីដែលបានបិទ នាត្រីមាសនេះ::**<br>- ២៣៨ (ស្រី៤២)ករណីបុគ្គល<br>- ៥0 ករណីគ្រួសារ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានចុះមូលដ្ឋានចំនួន ៤២ដង ក្នុងតំបន់ទាំង៥ នៃក្រុមតាមផ្ទះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំ ដើម្បីពង្រឹងការងារគ្រប់គ្រងករណី និងដោះស្រាយករណីរបស់ពួកគេ។<br>- បានផងក្រងរបាយការណ៍ប្រចាំខែ និងត្រីមាសដើម្បីផ្ញើរជូនមិត្តសំឡាញ់។<br><br>**ការគាំទ្របច្ចេកទេស** |

| | | |
|---|---|---|
| | - បុគ្គលិកចំនួន ៨០ នាក់នឹងទទួលបានការបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងករណី<br>- បុគ្គលិកចំនួន ៥០ នាក់ កំពុងធ្វើការជាអ្នកគ្រប់គ្រងករណី<br>- ជំនួយការបច្ចេកទេស នឹងផ្តល់ការគាំទ្របច្ចេកទេសជាទៀងរាល់សប្តាហ៍តាមរយៈការងារនៅមូលដ្ឋានជាមួយក្រុមការងារទាំងអស់<br>- កិច្ចប្រជុំស្តីពីការគ្រប់គ្រងករណី នឹងរៀបចំ និងធ្វើឡើងទៀងរាល់សប្តាហ៍នៅគ្រប់តំបន់ទាំងអស់<br>**ឧបករណ៍**<br>- សៀវភៅណែនាំស្តីពីការគ្រប់គ្រងករណី នឹងរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជាទៀងរាល់ឆ្នាំ និងចែករំលែកដល់ក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៤០នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | - បុគ្គលិកមិត្តសំឡាញ់ចំនួន ៤៧ នាក់ (ស្រី ២០នាក់) បានទទួលការបណ្តុះបណ្តាលស្តីពីចិត្តសាស្ត្រសង្គម ឧទេសនាមដោយអ្នកឯកទេសគ្រប់គ្រងករណីដោយមានការគាំទ្រពីហ្វ្រេនឡអិនធើណាសិនណល។<br>- បន្តការគាំទ្រដល់ប្រធានក្រុមគ្រប់តំបន់ និងអ្នកគ្រប់គ្រងករណីក្នុងការអនុវត្តប្រព័ន្ធនៃការគ្រប់គ្រងករណី។<br>- បុគ្គលិក ៥០នាក់ កំពុងធ្វើការជាអ្នកគ្រប់គ្រងករណីនៅក្នុងត្រីមាសនេះ។<br>- បានផ្តល់វគ្គរំលឹកស្តីពី ការគ្រប់គ្រងករណីដល់បុគ្គលិកមិត្តសំឡាញ់ និងកល្យាណមិត្តចំនួន ០៨ (ស្រី ០៣នាក់) នៅថ្ងៃទី៨-៩ ខែឧសភា ឆ្នាំ២០១២។<br>- កិច្ចប្រជុំគ្រប់គ្រងករណីបានរៀបចំនិងធ្វើឡើងទៀងរាល់សប្តាហ៍ជាមួយនិង ប្រធានតំបន់នៃក្រុមតាមថ្នល់ និងអ្នកគ្រប់គ្រងករណីនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>- ៩០% នៃករណីនៅមជ្ឈមណ្ឌលអប់រំបានដំរះ ដោយអ្នកឯកទេសគ្រប់គ្រងករណី ដោយកិច្ចសហការជាមួយអ្នកគ្រប់គ្រងករណី និងជំនួយការបច្ចេកទេស របស់អង្គការហ្វ្រេនឡអ៊ិនធើណាសិនណល។<br>**ឧបករណ៍**<br>- សៀវភៅណែនាំស្តីពីការគ្រប់គ្រងករណីដែលបានអនុវត្តន៍នៅក្នុង ត្រីមាសនេះ។<br>- សៀវភៅណែនាំស្តីពីការគ្រប់គ្រងករណី បានបង្កើត និង ផ្តល់វគ្គបណ្តុះបណ្តាលដើម្បីគាំទ្រដល់អ្នកគ្រប់គ្រងករណី។<br>**ដៃគូ**<br>- បានទស្សនកិច្ចនៅមជ្ឈមណ្ឌលសម្រាប់កុមារ/យុវវ័យសម្រាប់សុខភាពផ្លូវចិត្តនៃអ |

| | | |
|---|---|---|
| | | ង្គការកីឡាតាស ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្មដោយមានកិច្ច សហការពីអង្គការប្រេហ្ទ្បអ៊ិនធើណាសិនណល។<br>- បានចូលរួមកិច្ចប្រជុំនៃបណ្តាញគាំទ្រសេវាសង្គមនៃអង្គការនីញ៉ូម៉ូកម្ពុជាស្តីពីការបង្កើតសៀវភៅសេវា និងបទបង្ហាញពីសេវាកម្មនៃអង្គការនីមួយៗ នៅភោជនីដ្ឋានឡឺរ៉ាត នៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១២។<br>- បានចូលរួមទិវាសិទ្ធិកុមារអន្តរជាតិ នៅពន្លទាកា ស្រែសជាមួយអង្គការផ្សេងទៀត ដែលរៀបចំដោយអង្គការការពារយុត្តិធម៌កុមារ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១២<br>- បានចូលរួមសិក្ខាសិលាស្តីពី ក្រមសីលធម៌ និង សិទ្ធិមនុស្ស សម្រាប់អ្នកផ្តល់សេវា ដើម្បីប្រឆាំងលើការជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា រៀបចំដោយគម្រោងទីភ្នាក់ងារអង្គការសហប្រជាជាតិលើការជួញដូរមនុស្ស (UNIAP) នៅថ្ងៃទី ០៧-០៨ ខែមិថុនា ឆ្នាំ២០១២ ។<br>- បានចូលរួមប្រជុំជាមួយអង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ ស្តីពីការជ្រើសរើសប្រធាន និង អនុប្រធាន ដើម្បីសម្របសម្រួល កិច្ចប្រជុំសមាជិករបស់អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២។ |
| **៥. ៥ ក្រុមជំនាញផ្នែកគ្រឿងញៀន** | **លទ្ធផលរំពឹងទុក:**<br>- ម្ហូប/ស៊ីរ៉ាំងចំនួន ២០០,០០០ នឹងចែកចាយដល់យុវវ័យ<br>- សេវាលើការកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀនចំនួន ៧០,០០០ សេវា នឹងផ្តល់ជូនយុវវ័យ<br>- កុមារ/យុវវ័យចំនួន ២០០នាក់ នឹងទទួលបានសេវាបន្សាបគ្រឿងញៀន និងស្តារនីតិសម្បទា (យកទិន្នន័យ ពីក្រុមតាមផ្ទះ) | **លទ្ធផលសំរេចបាន:**<br>- ម្ជុល/ស៊ីរ៉ាំងចំនួន ៣៦,១៥០ បានចែកចាយដល់យុវវ័យ<br>- សេវាលើការកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀនចំនួន ១៤,៩០១ សេវាបានផ្តល់ជូនយុវវ័យ<br>- កុមារ/យុវវ័យចំនួន ៥៦នាក់ បានទទួលសេវាបន្សាបគ្រឿងញៀន និងស្តារនីតិសម្បទា នាត្រីមាសនេះ |

| | | |
|---|---|---|
| | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករជាលក្ខណៈស្តង់ដា នៃកម្មវិធីប្រេ្វនឡអ៊ិនធើណាសិនណលសម្រាប់សកម្មភាពគ្រឿងញៀន<br>- ការវាយតម្លៃលើសកម្មភាពដែលទាក់ទងជាមួយគ្រឿងញៀន (បំណិនជីវិត ការកាត់បន្ថយគ្រោះថ្នាក់នៃថ្នាំញៀនការបន្សាបគ្រឿងញៀន)<br>- ផងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយលើការស្ទង់មតិគ្រឿងញៀនប្រចាំឆ្នាំ<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក១០០%នឹងទទួលបានការបណ្តុះបណ្តាលលើចំណេះដឹងគ្រឿងញៀនជាមូលដ្ឋាន<br>- នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍ តាមរយៈការងារនៅតាមមូលដ្ឋានជាមួយក្រុមទាំងអស់<br>**ឧបករណ៍**<br>- សម្ភារៈអប់រំទៅលើគ្រឿងញៀននឹងត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>- សៀវភៅណែនាំនឹងរៀបចំអនុវត្តនិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៣០ នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ពង្រឹងការប្រមូលទិន្នន័យនៃ អ្នកប្រើប្រាស់គ្រឿងញៀន ជាមួយក្រុមតាមដាន និងវាយតម្លៃនិងបុគ្គលិកគ្រឿងញៀន ។<br>- បានផងក្រងរបាយការណ៍ប្រចាំខែ/ត្រីមាសជូនមិត្តសំឡាញ់ អង្គការប្រេ្វនឡអ៊ិនធើណាសិនណល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងម្ចាស់មូលនិធិ AusAid/HAARP ។<br>- បានធ្វើការប៉ាន់ប្រមាណប្រចាំខែលើកម្មវិធីម្ជុល/ស៊ីរាំងជាមួយអ្នកចាក់គ្រឿងញៀន នៅគ្រប់តំបន់ទាំងអស់នៃក្រុមតាមផ្ទាល់ ដោយមានកិច្ចសហការពីអង្គការប្រេ្វនឡអ៊ិនធើណាសិនណល។<br>- អ្នកឯកទេសគ្រឿងញៀន បានធ្វើការប៉ាន់ប្រមាណសហគមន៍វាលស្បូវដោយកិច្ចសហការជាមួយក្រុមអ្នកឯកទេសផ្សេងទៀត និងបុគ្គលិកម្ចាអំពៅ ដោយ យោងទៅផែនការយុទ្ធសាស្រ្តថ្មីរបស់អង្គការមិត្តសំឡាញ់ក្នុងឆ្នាំ ២០១២ ។<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកចំនួន ០៦នាក់ បានទទួលការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សម្ភារៈកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀន។<br>- បានចុះមូលដ្ឋានចំនួន ៦៦ដង ក្នុង ៥តំបន់មណ្ឌលសំចោលតេ មណ្ឌលស្នាក់នៅបណ្តោះអាសន្ន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស។<br>**ឧបករណ៍**<br>- ធ្វើការតាមដានលើការអនុវត្តសម្ភារៈអប់រំ លើការកាត់បន្ថយភាពមានគ្រោះថ្នាក់ |

| | | |
|---|---|---|
| | - ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | ដោយគ្រឿងញៀន និងសម្ភារៈអប់រំលើការបង្កាទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ជាមួយក្រុមតាមថ្នល់ក្នុងគោលបំណងដើម្បីធ្វើការកែលំអរប្រសិនបើចាំបាច់។<br>- សៀវភៅណែនាំសម្រាប់ផ្ទះបៃតង បានបញ្ចប់ជាមួយជំនួយការបច្ចេកទេសនៃអង្គការប្រេនឡអ៊ិនធើណាសិនណល។<br>- បន្តដំណើការក្រុមណាកូទិចអាណាមិក Narcotic Anonymous ដើម្បីជួយអតីតអ្នកប្រើប្រាស់គ្រឿងញៀន អោយបន្តការចាក់ផុតពីការត្រឡប់ទៅប្រើប្រាស់គ្រឿងញៀនវិញ ដែលពួកគេកំពុងសិក្សានៅមជ្ឈមណ្ឌលអង្គការមិត្តសំឡាញ់ដោយកិច្ចសហការជាមួយប្រេនឡអ៊ិនធើណាសិនណល។<br>**ដៃគូ**<br>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:<br>- បានចូលរួមកិច្ចប្រជុំយ៉ាងទៀតទាត់ជាមួយអង្គការសហប្រជាជាតិ អង្គការអន្តជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំផែនយុទ្ធសាស្ត្រ ៥ឆ្នាំសំរាប់គម្រោងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២០១១-២០១៥ ដើម្បីឆ្លើយតបនឹងសំណូមពរនៃការបញ្ចប់គម្រោងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ០២នាក់ បានចាត់តាំងចូលរួមនៅក្នុងដំណើរនៃការរៀបចំផែនទីនៃអ្នកប្រើប្រាស់គ្រឿងញៀនជាមួយក្រុមការងារថ្នាក់ជាតិ ដឹកនាំដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជម្ងឺ អេដស៍ សើស្បែក និងកាមរោគ។<br>- បានចូលរួមប្រជុំយ៉ាងទៀតទាត់ជាមួយក្រុមចំបង សម្របសម្រួលដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការសហប្រជា |

| | | |
|---|---|---|
| | | ជាតិ ដើម្បីរៀបចំបទដ្ឋានទិតិវិធីសម្រាប់ក្រុមងាយរងគ្រោះបំផុតពាក់ព័ន្ធទៅនឹងនារីបំរើសេវាកម្សាន្ត ក្រុមប្រុសស្រឡាញ់ប្រុស អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើគ្រឿងញៀនចាក់តាមសរសៃបន្ទាប់ពីក្រុមបច្ចេកទេស២ក្រុមបានធ្វើការប៉ាន់ប្រមាណជាមួយក្រុមគោលដៅរបស់មិត្តសំឡាញ់។<br>- មន្ត្រីសង្កាត់ចំនួន ១៨នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ និង ការការពារកុមារ ព្រមទាំងចុះមូលដ្ឋាន រៀបចំដោយអង្គការមិត្តសំឡាញ់ និងប្រេនឡូអ៊ិនធើណាសិនណល នាថ្ងៃទី ២៨-២៩ ខែមិថុនា ឆ្នាំ២០១២ ។<br>**ព្រឹត្តិការណ៍និងរំលេចសម្គាល់ពិសេស**<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ០៥នាក់ និងកុមារចំនួន ៣០នាក់ បានចូលរួមទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោមប្រធានបទ "រួមគ្នាសម្រាប់សុខភាពនិង សហគមន៍គ្មានគ្រឿងញៀន "នៅពហុកីឡដ្ឋានជាតិអូឡាំពិក ដែលមានអ្នកចូលរួមជាង ១០,០០០នាក់ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ ។<br>- កុមារ/យុវវ័យ និងគ្រួសារប្រមាណ១,១០០នាក់បានចូលរួមសកម្មភាពទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតំបន់ អណ្តូង ផ្សារអំពៅ និងអង្គការមិត្តសំឡាញ់ នាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១២ ។ |
| **៥.៦ ក្រុមឯកទេសផ្នែកអប់រំក្រៅប្រព័ន្ធ** | **លទ្ធផលរំពឹងទុក:**<br>- សេវានៃការអប់រំក្រៅប្រព័ន្ធចំនួន ១២២,០០០ នឹងផ្តល់ដល់កុមារ/យុវវ័យនៅតាមថ្នាល់ មជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ** | **លទ្ធផលសំរេចបាន:**<br>សេវានៃការអប់រំក្រៅប្រព័ន្ធចំនួន ៣១,៣២៥ (ស្រី ១៣,០៧៤ ដង) បានផ្តល់ដល់កុមារ/យុវវ័យ នៅតាមថ្នាល់ មជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។ |

| | | |
|---|---|---|
| | - ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធី ប្លែនអ៊ិនធើណាសិនណលសម្រាប់សកម្មភាព អប់រំក្រៅប្រព័ន្ធជាមួយក្រុមអប់រំតាម ថ្នល់<br>- ចងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និង រដ្ឋាភិបាល<br>- ការវាយតម្លៃលើសកម្មភាពអប់រំក្រៅប្រព័ន្ធ<br>- រៀបចំការស្រាវជ្រាវមួយ<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក៦០នាក់នឹងទទួលបានការបណ្តុះបណ្តាលស្តីពីសកម្មភាពអប់រំក្រៅប្រព័ន្ធ<br>- ជំនួយការបច្ចេកទេស នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈ ការចុះនៅតាមមូលដ្ឋាន ជាមួយមជ្ឈមណ្ឌលអប់រំ និងក្រុមការងារតាមថ្នល់<br>**ឧបករណ៍**<br>- សម្ភារៈអប់រំក្រៅប្រព័ន្ធថ្មី នឹងត្រូវបង្កើតនិងធ្វើបច្ចុប្បន្នភាព<br>- សៀវភៅណែនាំ ស្តីពីការអប់រំក្រៅប្រព័ន្ធ នៅតាមថ្នល់ ក្នុងមណ្ឌល និងសមាហរណកម្មទៅសាលារដ្ឋ នឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- នឹងបង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែក ជាមួយក្រុមការងារទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៣០នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានចុះមូលដ្ឋានចំនួន១៨ដង នៅ៥តំបន់ ដើម្បីធានាថាឧបករណ៍សិក្សាបានប្រើប្រាស់ ព្រមទាំងគាំទ្រអ្នកអប់រំលើវិធីសាស្ត្រក្នុងការដំណើរការឧបករណ៍សិក្សា។<br>- បានចងក្រងរបាយការណ៍ប្រចាំត្រីមាស ជូនមិត្តសំឡាញ់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ។<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ១៥នាក់ (ស្រី០៦នាក់) បានទទួលវគ្គរំលឹកឡើងវិញស្តីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សា ឧទ្ទេសនាមដោយអ្នកឯកទេសអប់រំក្រៅប្រព័ន្ធ នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១២ ។<br>- គ្រូបង្រៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញជីវៈអង្គការមិត្តសំឡាញ់ចំនួន ១៣ (ស្រី ០៦នាក់) បានចូលរួមធ្វើការអង្កេត ចែកចាយបទពិសោធន៍ បញ្ហាប្រឈម និងដំណោះស្រាយដ៏សមរម្យ នៅក្នុងការបង្រៀន រៀបចំដោយអ្នកឯកទេសអប់រំក្រៅប្រព័ន្ធ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ។<br>**ឧបករណ៍**<br>- ល្បែងកម្សាន្តថ្មីចំនួន០៣ បានពង្រាង (កម្សាន្តអក្សរសាស្ត្រចំនួន២ និង វិទ្យាសាស្ត្រចំនួន១ ) ។<br>- សៀវភៅណែនាំ ស្តីពីការអប់រំក្រៅប្រព័ន្ធក្នុងមណ្ឌល កំពុងកែសម្រួលបន្ទាប់ពីអ្នកសម្របសម្រួលកម្មវិធី បានត្រួតពិនិត្យ ហើយនឹងបញ្ចប់នៅក្នុងត្រីមាសបន្ទាប់។<br>- សៀវភៅណែនាំចំនួន២ ស្តីពីអប់រំក្រៅប្រព័ន្ធនៅតាមថ្នល់ និងនៅសាលារដ្ឋបាន |

| | | |
|---|---|---|
| | | ត្រួតពិនិត្យ ដោយអ្នកសម្របសម្រួលកម្មវិធី។<br>**ដៃគូ**<br>- បុគ្គលិកអង្គការកណ្ដាលមិត្តមណ្ឌលចោមចៅចំនួន ០៧ នាក់(ស្រី២នាក់) បានទទួលការបណ្ដុះបណ្ដាលស្ដីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សា នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២។<br>- បុគ្គលិករដ្ឋាភិបាលចំនួន ៣៣ (ស្រី ១៦នាក់) បានទទួលការបណ្ដុះបណ្ដាល ស្ដីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សាដោយមានកិច្ចសហការពី Aide et Action - Cambodia.<br>**ព្រឹត្តិការណ៍និងអំណត់សម្គាល់ពិសេស**<br>- បានធ្វើបទបង្ហាញស្ដីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សាទៅដល់អង្គការផ្សេងៗនៅក្រុមការងារផ្នែកអប់រំក្រៅប្រព័ន្ធ រៀបចំដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល(NEP) នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១២។<br>- បានចូលរួមប្រជុំក្រុមការងារផ្នែកអប់រំក្រៅប្រព័ន្ធ ស្ដីពីមណ្ឌលសិក្សានៅសហគមន៍ រៀបចំដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នៅថ្ងៃទី ១0 ខែមេសា ឆ្នាំ២០១២ ។<br>- បុគ្គលិករបស់អង្គការ Planet Wheeler បានមកទស្សនកិច្ចសិក្សាលើដំណើរការគម្រោង ថែមទាំងបានពិភាក្សាគ្នាពីផែនការអនាគតរបស់គម្រោង នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២ ។ |
| **៥.៧ ក្រុមឯកទេសផ្នែកបំណិនជីវិត** | **លទ្ធផលរំពឹងទុក:**<br>- សេវាអប់រំបំណិនជីវិតចំនួន ២៨0,000 នឹងផ្ដល់ដល់កុមារ/យុវវ័យ<br>- សេវាអប់រំបំណិនជីវិតចំនួន ៩0,000 នឹងផ្ដល់ដល់អាណាព្យាបាល | **លទ្ធផលសំរេចបាន:**<br>- សេវាអប់រំបំណិនជីវិតចំនួន ៦៧,៥៥៥ បានផ្ដល់ដល់កុមារ/យុវវ័យ<br>- សេវាអប់រំបំណិនជីវិតចំនួន ២៥,៤០៧ បានផ្ដល់ដល់អាណាព្យាបាល |

| | | |
|---|---|---|
| | - ស្រោមអនាម័យចំនួន ២៥០,០០០ នឹងចែកជូនយុវវ័យ និងអាណាព្យាបាល<br>- មិត្តអប់រំមិត្តចំនួន ២៧០នាក់ (ភ្នាក់ងារសុវត្ថិភាពចំនួន ១៥០នាក់)<br>- សេវាអប់រំមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន ៥២,០០០<br>- សេវាអប់រំសុខភាពបន្តពូជចំនួន ៥៥,០០០<br>- សេវាអប់រំគ្រឿងញៀនចំនួន ៥០,០០០<br>- សេវាអប់រំសិទ្ធិកុមារចំនួន ២៥,០០០<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យជាសូចនាករលក្ខណស្តង់ដានៃកម្មវិធីប្រហ្វ្រាន្សអ៊ិនធើណាសិនណលសម្រាប់បំណិនជីវិត ជាមួយការអប់រំក្រុមការងារតាមថ្នល់<br>- ផងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- ការវាយតម្លៃលើសកម្មភាពបំណិនជីវិត<br>- រៀបចំការស្រាវជ្រាវមលើបំណិនជីវិតប្រចាំឆ្នាំ<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកចំនួន ៥០នាក់នឹងទទួលបានបណ្តុះបណ្តាលស្តីពីសកម្មភាពបំណិនជីវិត<br>- នឹងផ្តល់គាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈការធ្វើការនៅតាមមូលដ្ឋាន ជាមួយការអប់រំក្រុមតាមថ្នល់<br>**ឧបករណ៍**<br>- សម្ភារៈអប់រំថ្មីនឹងបង្កើត និងធ្វើបច្ចុប្បន្នភាព<br>- សៀវភៅណែនាំស្តីពីបំនិនជីវិតនឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ | - ស្រោមអនាម័យចំនួន ៤០,៥០០ បានចែកជូនយុវវ័យ និងអាណាព្យាបាល<br>- មិត្តអប់រំមិត្តចំនួន ២៥០នាក់ (ស្រី ៨៤នាក់ ) ក្នុងនោះមានភ្នាក់ងារសុវត្ថិភាព ចំនួន ១៩២នាក់ (ស្រី៥២នាក់)<br>- សេវាអប់រំមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន ១២,០០១<br>- សេវាអប់រំសុខភាពបន្តពូជចំនួន ១២,៣៨៧<br>- សេវាអប់រំគ្រឿងញៀនចំនួន ១២,០៥១<br>- សេវាអប់រំសិទ្ធិកុមារចំនួន ១០,១៤០<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ការអង្កេតស្ទាបស្ទង់លើការយល់ដឹងពីមេរោគអេដស៍/ជំងឺអេដស៍មុនការបង្រៀន នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមតាមថ្នល់និងសហគមន៍។<br>- បានផងក្រងរបាយណ៍ប្រចាំខែ និងត្រីមាសជូនមិត្តសំឡាញ់ និងអង្គការជំនួយរបស់ វិហារដាណឺម៉ាក។<br>**ការគាំទ្របច្ចេកទេស**<br>- បានចុះមូលដ្ឋានចំនួន៤២ដង នៅតំបន់ទាំង៥ នៃក្រុមតាមថ្នល់ មណ្ឌលសំចត មជ្ឈមណ្ឌលអប់រំនិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>- បុគ្គលិកកោដនីយដ្ឋានចំនួន ១២នាក់ (ស្រី០៣នាក់) បានទទួលវគ្គរំលឹកឡើងវិញ ស្តីពីសុខភាពបន្តពូជ មេរោគអេដស៍/ជម្ងឺអេដស៍និងកាមរោគ ។<br>- បានចូលរួមជួយសម្របសម្រួលនៅក្នុងក្រុមគាំទ្រផ្លូវចិត្តជាមួយអាណាព្យាបាលនៅ តំបន់អូឡាំពិករៀងរាល់២សប្តាហ៍ ។<br>**ឧបករណ៍** |

| | | |
|---|---|---|
| | **ដៃគូ**<br>- បុគ្គលិកអង្គការដៃគូចំនួន ៣០នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | - សម្ភារៈអប់រំសុវត្ថិភាព និងអនាម័យសម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ បានកែសម្រួល បន្ទាប់ពីបានត្រួតពិនិត្យ ដោយអ្នកសម្របសម្រួលកម្មវិធី។<br>- បានរៀបចំផ្សព្វផ្សាយកម្មវិធីការការពារស្ត្រីមានគភ៌សម្រាប់យុវតី នៅកំពុងរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>**ដៃគូ**<br>- បានទស្សនកិច្ចនៅអង្គការភាពញញឹមនៃកុមារ ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្ម ដោយមានកិច្ចសហការពីអង្គការប្រេនឡអ៊ិនធើណាសិនណល ។<br>- អង្គការជំនួយរបស់វិហារដាណឺម៉ាក បានវាយតម្លៃគម្រោងមេរោគអេដស៍/ជម្ងឺអេដស៍ និងថែមទាំងសម្ភាសន៍កុមារ ចំនួន១៦នាក់ (ស្រី០៦នាក់) នៅមជ្ឈម ណ្ឌលបណ្តុះ បណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ។<br>- បុគ្គលិកភឿនភឿន បានទទួលវគ្គតម្រង់ទិសពីគម្រោងបំណិនជីវិត នៅអង្គការមិត្តសំឡាញ់នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១២ ។<br>- យុវតី០១នាក់ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ បានសម្ភាសន៍ដោយបុគ្គលិកម៉ារីស្តុប ស្តីសុខភាពបន្តពូជពាក់ព័ន្ធទៅនឹងមេរោគអេដស៍/ជម្ងឺអេដស៍ នៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១២ ។ |
| **៥.៨ ក្រុមឯកទេសបណ្តាញសុវត្ថិភាពកុមារ** | **លទ្ធផលរំពឹងទុក:**<br>- នឹងមានសមាជិកបណ្តាញសុវត្ថិភាពកុមារនាពេលបច្ចុប្បន្នចំនួន ១,០០០នាក់ រួមបញ្ចូលបណ្តាញសុវត្ថិភាពកុមារនៅសហគមន៍ នៅរាជធានីភ្នំពេញនិងកំពង់ចាម<br>- កុមារចំនួន ១,១០០នាក់ នឹងទទួលបានការការពារនិងបញ្ជូនដោយសមាជិកបណ្តាញសុវត្ថិភាពកុមារ | **លទ្ធផលសំរេចបាន:**<br>- សមាជិកបណ្តាញសុវត្ថិភាពកុមារនាពេលបច្ចុប្បន្នមានចំនួន ៦៤៧នាក់ (ស្រី១០០នាក់) (ម៉ូតូឌុប ២៦៨នាក់, ម៉ូតូរ៉ឺម៉ក ២២៥នាក់, តាក់ស៊ី៦នាក់) រួមបញ្ចូលបណ្តាញសុវត្ថិភាពកុមារនៅសហគមន៍ចំនួន ១៤៨នាក់ (ស្រី១០០នាក់) នៅរាជធានីភ្នំពេញនិងកំពង់ចាម។ |

| | | |
|---|---|---|
| | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធីហ្វ្រេនអ៊ិនធើណាស៊ិនណលសំរាប់បណ្តាញសុវត្ថិភាពកុមារ<br>- ការវាយតម្លៃលើបណ្តាញសុវត្ថិភាពកុមារក្នុងរាជធានីភ្នំពេញនិងខេត្តកំពង់ចាម<br>- ចងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយ<br><br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក១00%នឹងទទួលបានបណ្តុះបណ្តាលស្តីពីសកម្មភាពបណ្តាញសុវត្ថិភាពកុមារ<br>- នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈការចុះមូលដ្ឋានជាមួយក្រុមការងារទាំងអស់<br>- ពិនិត្យមើលសំភារៈនៅក្នុងឃ្លាំង និងបញ្ជាទិញសំភារៈថ្មីៗសម្រាប់សមាជិកបណ្តាញសុវត្ថិភាពកុមារ<br>**ឧបករណ៍**<br>- សម្ភារៈអប់រំបណ្តាញសុវត្ថិភាពកុមារនឹងត្រូវពិនិត្យនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>- សៀវភៅណែនាំស្តីពីបណ្តាញសុវត្ថិភាពកុមារ នឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ | - សរុបចំនួន ១៤២នាក់ នៃការកុមារ/យុវវ័យបានទទួលការការពារ និងបញ្ជូនមកអង្គការមិត្តសំឡាញ់ មន្ទីរពេទ្យ និងហៅទូរស័ព្ទទៅទូរស័ព្ទបន្ទាន់និងប៉ូលីស ដោយសមាជិកបណ្តាញសុវត្ថិភាពកុមារ។<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- សមាជិកសុវត្ថិភាពកុមារបានតាមដាន និងរំលឹកឡើងវិញចំនួន ៤,៤៧៧ដង ក្នុងត្រីមាសនេះ។<br>- សមាជិកសុវត្ថិភាពចំនួន ១0២នាក់ បានតាមដាន ដោយការប្រើប្រាស់ទម្រង់ នៃការតាមដាន ធ្វើឡើងដោយបុគ្គលតាមថ្នល់ នៅភ្នំពេញនិងកំពង់ចាម។<br>- បានចងក្រងរបាយការណ៍ប្រចាំត្រីមាស ជូនមិត្តសំឡាញ់ និងអង្គការហ្វ្រេនអ៊ិនធើណាស៊ិនណល ។<br>**ការគាំទ្របច្ចេកទេស**<br>- បានចុះមូលដ្ឋានចំនួន ៦៥ដង ដើម្បីជួបប្រជុំជាមួយសមាជិកសុវត្ថិភាពកុមារ និងគាំទ្រដល់បុគ្គលិកនៅតំបន់ទាំង៥នៃក្រុមតាមថ្នល់។<br>- បុគ្គលិកក្រុមតាមថ្នល់ចំនួន ៣៨នាក់ បានទទួលវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំ នៅហ្វ្រេនអ៊ិនធើណាស៊ិនណលនាថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១២ ។<br>**ឧបករណ៍**<br>- ទម្រង់នៃការតាមដានសមាជិកសុវត្ថិភាពកុមារបានកំពុងអនុវត្តន៍ដោយបុគ្គលិកមិត្តសំឡាញ់។<br>- សៀវភៅណែនាំ ស្តីពីបណ្តាញសុវត្ថិភាពកុមារបានបណ្តុះបណ្តាលដល់បុគ្គលិកតាមថ្នល់និងបុគ្គលិកហ្វ្រេនអ៊ិនធើណាស៊ិនណល។ |

| | | |
|---|---|---|
| | **ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៤០នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាលតាមរយៈប្រេនឡអ៊ិនធើណាសិនណល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | **ដៃគូ**<br>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:<br>- បុគ្គលិកប្រេនឡអ៊ិនធើណាសិនណលចំនួន១៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការការពារកុមារ និងសៀវភៅណែនាំស្តីពីបណ្តាញសុវត្ថិភាពកុមារនៅប្រេនឡអ៊ិនធើណាសិនណលនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០១២។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ៣៤នាក់ ទទួលវគ្គបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំស្តីពីបណ្តាញសុវត្ថិភាពកុមារ។<br>**ព្រឹត្តិការណ៍និងកំណត់សម្គាល់ពិសេស**<br>- សមាជិកបណ្តាញសុវត្ថិភាពចំនួន ១៥១នាក់ ក្នុងនោះមានថ្មីចំនួន ៥១នាក់ថ្មី មកពីសហគមន៍អណ្តូង ផ្សារអំពៅ និងមាត់ទន្លេ បានទទួលសញ្ញាបត្រនៅក្លឹបប្រេនឡ នៅថ្ងៃទី០២/២៣ ខែមិថុនា ឆ្នាំ២០១២។<br>- សមាជិកបណ្តាញសុវត្ថិភាពចំនួន ៦៦នាក់ បានលប់ឈ្មោះចេញពីបញ្ជីឈ្មោះសមាជិកសុវត្ថិភាពកុមារក្នុងត្រីមាសនេះ ដោយសារពួកគាត់មិនបានគោរពតាម គោលការណ៍ការពារកុមារ ផ្លាស់ប្តូរមុខរបរនិងអ្នកខ្លះទៀតត្រឡប់ទៅស្រុកកំណើតវិញ។ |